## តើតួនាទីបុគ្គលិកការងារសង្គមកិច្ចរបស់លោកអ្នក ធ្វើអ្វី ?



បុគ្គលិកការងារសង្គមកិច្ចរបស់លោកអ្នក នឹងជម្រាបប្រាប់លោកអ្នក ឲ្យបានជ្រាបអំពីការគំរាមកំហែងសុវត្ថិភាពនានា ដែលនាំឲ្យគេដកយកកូនរបស់លោកអ្នក ទៅរកអ្នកអាណាព្យាបាលណាម្នាក់ ឲ្យជួយចិញ្ចឹមបីបាច់នៅក្រៅផ្ទះរបស់លោកអ្នក។ បុគ្គលិកទាំងនោះនឹងធ្វើការជាដៃគូជាមួយលោកអ្នក ដើម្បីបំពេញសេចក្តីត្រូវការនានារបស់លោកអ្នក និងជួយផ្តល់សេវាទ្រទ្រង់ផ្សេងៗជូនលោកអ្នក ដើម្បីឈានទៅកាត់បន្ថយ ឬលុបបំបាត់ទាំងស្រុងនូវការគំរាមកំហែងសុវត្ថិភាពលើកូនរបស់លោកអ្នក។

## តើបដ្តឹងលិខិតកូនក្រោមបន្ទុកជាអ្វី ?

បដ្តឹងលិខិតកូនក្រោមបន្ទុក (dependency petition) គឺជាលិខិតលាយលក្ខណ៍អក្សរ ដែលស្នើសុំតុលាការអំពីបញ្ហានានា ដែលបណ្តាលឲ្យកូនរបស់លោកអ្នកទទួលរងនូវការរំលោភបំពាន, ការធ្វេសប្រហែស, ឬការបោះបង់ចោល ហើយឪពុកម្តាយមិនអាចផ្តល់សុវត្ថិភាពជូនកូនរបស់ខ្លួនបាន។ បដ្តឹងលិខិតកូនក្រោមបន្ទុកស្នើសុំតុលាការ ឲ្យធ្វើអន្តរាគមន៍ និងចាត់វិធានការការពារកូនរបស់លោកអ្នក ឲ្យរួចផុតពីគ្រោះថ្នាក់ ហើយរដ្ឋនឹងទាមទារយកសិទ្ធិផ្តល់អាណាព្យាបាលស្របច្បាប់លើកូនរបស់លោកអ្នកជាបណ្តោះអាសន្ន។ នាយកដ្ឋានគ្រប់គ្រងកុមារ (Children's Administration) នឹងដាក់បដ្តឹងលិខិតកូនក្រោមបន្ទុក ទៅតុលាការ នៅពេលគេជឿថា កុមារណាម្នាក់ហៀបនឹង ឬកំពុងមានបញ្ហាប្រឈមគ្រោះថ្នាក់។ កុមារទាំងឡាយនឹងត្រូវគេអនុញ្ញាតឲ្យវិលទៅរស់នៅផ្ទះវិញ នៅពេលណាការគំរាមកំហែងក្នុងផ្ទះរបស់គ្រួសារទាំងនោះត្រូវបានគ្រប់គ្រង និងចាត់ចែងដោយសុវត្ថិភាពឡើងវិញ។

## មេធាវី

លោកអ្នកមានសិទ្ធិរកមេធាវីធ្វើជាតំណាងខ្លួន។ បើលោកអ្នកមិនមានប្រាក់ជួលមេធាវីដោយខ្លួនឯងបាន ដោយសារប្រាក់ចំណូលរបស់លោកអ្នកតិច, នោះតុលាការនឹងផ្តល់មេធាវីម្នាក់ជូនលោកអ្នក។

## CASA/GAL

CASA (Court Appointed Special Advocate/អ្នកគាំពារពិសេសចាត់តាំងដោយតុលាការ) និង GAL's (Guardians ad Litem/អ្នកអាណាព្យាបាលចាត់តាំងដោយតុលាការ) នឹងត្រូវបានចាត់តាំងដោយចៅក្រម ដើម្បីគាំពារកូនរបស់លោកអ្នក។ CASA ឬ GAL នឹងជម្រាបចៅក្រមនៅក្នុងសវនាការតុលាការអំពីអ្វី ដែលគាត់ជឿថា អាចផ្តល់អត្ថប្រយោជន៍ដល់កូនរបស់លោកអ្នក និងអ្វីដែលកូនរបស់លោកអ្នកត្រូវការ។ CASA ឬ GAL នឹងធ្វើការយ៉ាងហ្មត់ចត់ដើម្បីធានាថា កូនរបស់លោកអ្នកទទួលបានគ្រប់ទាំងសេចក្តីសម្រេច ដែលតុលាការបានសម្រេច។



## អ្នកសម្រាប់ទាក់ទងនៅពេលមានការសំខាន់

ឈ្មោះរបស់បុគ្គលិកការងារសង្គមកិច្ច ៖

### លោកអ្នកត្រូវការមេធាវីឬ ?

ការិយាល័យមេធាវីចាត់តាំង ៖

ការិយាល័យរបស់អ្នកការពារក្តីសាធារណៈ ៖
ទូរស័ព្ទ ៖ 360-586-3164
អ៊ីមែល ៖ opd@opd.wa.gov

### ឈ្មោះ និងលេខទូរស័ព្ទរបស់ CASA/GAL ៖

> **ភ្នាក់ងារស៊ើបអង្កេតបណ្តឹងសាធារណៈរបស់គ្រួសារនិងកុមារ (Family and Children's Ombudsman)** នឹងស៊ើបអង្កេតក្តីពាក់ព័ន្ធបណ្តឹងស្តីពីចំណាត់ការជាក់ស្តែង ឬចំណាត់ការប្រយោលរបស់ទីភ្នាក់ងារ ដែលពាក់ព័ន្ធនឹងកុមារឬឪពុកម្តាយ ដែលជាប់ពាក់ព័ន្ធនឹងចំណាត់ការការពារកុមារ ឬសេវាសុខុមាលភាពកុមារ។
> ទូរស័ព្ទឥតគិតថ្លៃ ៖ 1-800-571-7321
> ទូស័ព្ទធម្មតា ៖ (206) 439-3870

> **ទូរស័ព្ទបន្ទាន់របស់នាយកដ្ឋានគ្រប់គ្រងកុមារ (Children's Administration Hotline)**
> ទូរស័ព្ទទៅ 1-866-ENDHARM (1-866-363-4276)
> *បម្រើការបន្ទាន់ 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយអាទិត្យ ដើម្បីតភ្ជាប់លោកអ្នកទៅនឹងការិយាល័យក្នុងមូលដ្ឋានដោយផ្ទាល់។*

> លោកអ្នកក៏អាចទាក់ទងទៅ **ការិយាល័យនាយដ្ឋានគ្រប់គ្រងកុមារផ្នែកទំនាក់ទំនងប្រចាំមណ្ឌល (Children's Administration Office of Constituent Relations)** តាមលេខ 1-800-723-4831 បានដែរ ដើម្បីសាកសួរ ឬស្វែងយល់អំពីនីតិវិធីដាក់បណ្តឹងផ្លូវការ។



Washington State Department of Social & Health Services
DSHS 22-1499 CA (1/13)

# ការស្វែងយល់អំពីនីតិវិធីតុលាការកូនក្រោមបន្ទុក



លោកអ្នកមានសិទ្ធិ ៖

- ទទួលបាននូវការរាប់រករាក់ទាក់ដោយគោរព
- យល់ដឹងអំពីអ្វីដែលកំពុងកើតឡើងលើសំណុំរឿងរបស់លោកអ្នក និងកូនរបស់លោកអ្នក
- ឲ្យគេរក្សាការសម្ងាត់លើពត៌មាននានារបស់លោកអ្នក

លោកអ្នកត្រូវទទួលខុសត្រូវលើការ ៖

- ចូលរួមរៀបចំផែនការចាត់ចែងទីកន្លែង ដែលលោកអ្នកចង់ឲ្យកូនរបស់លោកអ្នករស់នៅ
- ទៅមើលសុខទុក្ខកូនរបស់លោកអ្នក
- ប្រាប់បុគ្គលិកការងារសង្គមកិច្ចរបស់លោកអ្នក ឲ្យបានដឹងលេខទូរស័ព្ទ និងអាសយដ្ឋានថ្មីរបស់លោកអ្នក នៅពេលណាលោកអ្នកផ្លាស់ប្តូរ
- ពន្យល់ប្រាប់អំពីអ្វីដែលលោកអ្នកត្រូវការ ដើម្បីធ្វើជាឪពុក/ម្តាយល្អ

តួនាទីរបស់លោកអ្នកគឺ ៖

- ប្រាប់អំពីបំណងប្រាថ្នារបស់លោកអ្នក ក្នុងការរៀបចំផែនការរស់នៅជូនកូនរបស់លោកអ្នក
- បញ្ចេញមតិយោបល់របស់លោកអ្នក និងចូលរួមរៀបចំផែនការលើសំណុំរឿងរបស់លោកអ្នក

## សេចក្តីសំខាន់ៗដែលត្រូវដឹង

នៅគ្រាណាមួយក្នុងអំឡុងពេលកំពុងអនុវត្តន៍នីតិវិធីតុលាការ, ចៅក្រមនឹងសម្រេចថា គេអាចអនុញ្ញាតឲ្យកូនរបស់លោកអ្នក វិលទៅរស់នៅឯផ្ទះវិញដោយសុវត្ថិភាព។ ក៏ប៉ុន្តែ បើលោកអ្នកមិនអាចកែប្រែ ឲ្យស្របទៅតាមសភាពការជាចាំបាច់នានា ដើម្បីរក្សាសុវត្ថិភាពជូនកូនរបស់លោកអ្នកទេ, នោះលោកអ្នកអាចនឹងបាត់បង់សិទ្ធិជាឪពុកម្តាយរបស់កូននោះ។ នាយកដ្ឋានគ្រប់គ្រងកុមារនឹងផ្តល់ការឧបត្ថម្ភ និងសេវាជំនួយផ្សេងៗជូនលោកអ្នក ដើម្បីជួយបញ្ចៀសលោកអ្នកពីវិបត្តិនេះ ហើយវិលមករស់នៅជួបជុំកូនរបស់លោកអ្នកវិញ។

# តារាងកាលបរច្ឆេទនៃការអនុវត្តន៍នីតិវិធីតុលាការកូនក្រោមបន្ទុក

**សូមធ្វើយ៉ាងណាឲ្យប្រាកដថា លោកអ្នកបានពិគ្រោះយោបល់ជាមួយមេធាវីរបស់លោកអ្នកអំពីសវនាការតុលាការរបស់លោកអ្នក។**

### ការបញ្ជូនរបស់ CPS
នីតិវិធីចាប់ផ្តើមនៅទីនេះ

CPS បានទទួលការបញ្ជូនស្តីពីការរំលោភបំពានលើកូន ឬការទុកកូនចោល។ ការបញ្ជូននេះត្រូវបានវាយតម្លៃ និងយកមកពិនិត្យមើលដើម្បីបើកការស៊ើបអង្កេត ឬពិនិត្យបញ្ចប់។ កូននេះត្រូវបានដកចេញពីផ្ទះដោយ CPS ឬភ្នាក់ងារមានសមត្ថកិច្ច ប្រសិនបើពួកគេជឿថា វាមានការតម្រូវជាចាំបាច់ ឲ្យគេការពារកូននេះពីគ្រោះថ្នាក់ណាមួយ ដែលហៀបនឹងកើតឡើង។

**72 ម៉ោង យ៉ាងច្រើនបំផុត**

### កូនត្រូវបានដកយកទៅដាក់ក្រោមកិច្ចការពាររបស់រដ្ឋ

កូនត្រូវបានដកចេញពីការចិញ្ចឹមបីបាច់របស់លោកអ្នក ហើយដាក់ឲ្យសាច់ញាតិជួយចិញ្ចឹមនៅក្រៅផ្ទះ ឬឲ្យគ្រួសារណាមួយជួយចិញ្ចឹម។ សវនការស្តីពីទីជម្រកនឹងត្រូវធ្វើឡើងនៅក្នុងរយៈពេល 72 ម៉ោងបន្ទាប់ពីថ្ងៃដែលកូនរបស់លោកអ្នកត្រូវបានដកចេញពីផ្ទះរបស់លោកអ្នក។

### សវនាការស្តីពីទីជម្រក
(កូនរបស់លោកអ្នកអាចត្រូវបានអនុញ្ញាត ឲ្យវិលទៅរស់នៅផ្ទះវិញនៅក្រោយសវនាការតុលាការណាមួយ ដែលបានចុះជូនក្រោម)

នៅក្នុងសវនាការនេះ លោកអាចស្នើសុំតុលាការឲ្យផ្តល់មេធាវីម្នាក់ ជូនលោកអ្នក។ ចៅក្រមនឹងវិនិច្ឆ័យ ថាតើកូនលោកអ្នកចាំបាច់ត្រូវបន្តឲ្យគេជួយចិញ្ចឹមនៅក្រៅផ្ទះទេ ឬក៏អាចវិលទៅរស់នៅជាមួយលោកអ្នកវិញដោយសុវត្ថិភាពហើយ។ លោកអ្នកអាចស្នើសុំតុលាការ ឲ្យដាក់កូនរបស់លោកអ្នក ឲ្យសាច់ញាតិណាម្នាក់ជួយចិញ្ចឹម ជាជាងរកគ្រួសារណាផ្សេងជួយចិញ្ចឹម។ បើកូនលោកអ្នកនៅតែត្រូវបន្តឲ្យគេជួយចិញ្ចឹម, នោះបុគ្គលិកការងារសង្គមកិច្ចនឹងដាក់ពេល ឲ្យលោកអ្នកអាចទៅលេងកូន។

**30 ថ្ងៃ**

### សវនាការស្តីពីការបន្តផ្តល់ទីជម្រក
(នៅក្នុងតុលាការខ្លះ)

តុលាការនឹងវិនិច្ឆ័យម្តងទៀត ថាតើកូនរបស់លោកអ្នកចាំបាច់នៅតែត្រូវបន្តឲ្យគេជួយចិញ្ចឹមនៅក្រៅផ្ទះឬទេ ឬក៏អាចវិលទៅរស់នៅជាមួយវិញបានហើយ។ តុលាការនឹងត្រួតពិនិត្យមើលផែនការទៅលេងកូនរបស់លោកអ្នក និងទីកន្លែងដែលកូនរបស់លោកអ្នកកំពុងរស់នៅ។

**90 ថ្ងៃ**

### សវនាការកំណត់អង្គហេតុ
(នៅក្នុងរយៈពេល 75 ថ្ងៃ បន្ទាប់ពីថ្ងៃដាក់បណ្តឹងលិខិតកូនក្រោមបន្ទុកទៅតុលាការ)

បើលោកអ្នកនៅតែបន្តបដិសេធមិនឲ្យគេដកកូន ទៅឲ្យមនុស្សដទៃជួយចិញ្ចឹម, នោះតុលាការនឹងសួរសក្ខីកម្មពីលោកអ្នក និងពីសាក្សីដទៃៗទៀតអំពីការគំរាមកំហែងដល់សុវត្ថិភាពកូន ដែលនាយកដ្ឋានបានដាក់បណ្តឹងលិខិតកូនក្រោមបន្ទុកប្តឹងទៅតុលាការ។ តុលាការនឹងចេញសេចក្តីសម្រេចឲ្យកូនរបស់លោកអ្នករស់នៅក្រោមកិច្ចការពាររបស់រដ្ឋ ឬឲ្យកូនវិលទៅរស់នៅជាមួយលោកអ្នកវិញ ហើយលើកលែងការចោទប្រកាន់ពីបទរំលោភបំពាន ឬធ្វេសប្រហែសកូន ឬចេញដីកាបង្គាប់ថា កូនរបស់លោកអ្នកល្មមអាចវិលទៅរស់នៅជាមួយលោកអ្នកវិញ ក្រោមការពិនិត្យឃ្លាំមើលរបស់តុលាការ។

### សវនាការសម្រេចទោស
(នៅក្នុងរយៈពេល 90 ថ្ងៃ បន្ទាប់ពីថ្ងៃដាក់បណ្តឹងលិខិតកូនក្រោមបន្ទុកទៅតុលាការ)

បើកូនរបស់លោកអ្នកត្រូវបានប្រកាសថា ជាកូនត្រូវរស់នៅក្រោមកិច្ចការពាររបស់រដ្ឋ, នោះតុលាការនឹងបង្គាប់លោកអ្នក ឲ្យចូលរួមក្នុងសេវាអប់រំនានា ដើម្បីកាត់បន្ថយការគំរាមកំហែងសុវត្ថិភាពក្នុងផ្ទះរបស់លោកអ្នក។ តុលាការក៏នឹងចេញដំណោះស្រាយអំពីរឿងរ៉ាវដាក់កូនឲ្យគេជួយចិញ្ចឹម និងរឿងរ៉ាវទៅលេងឬទៅសួរសុខទុក្ខកូនផងដែរ។

**6 ខែ**

### សវនាការពិនិត្យមើលករណីកូនក្រោមបន្ទុកឡើងវិញ លើកទីមួយ

តុលាការនឹងពិនិត្យមើលការរីកចម្រើននៃទទួលសេវាអប់រំរបស់លោកអ្នក និងសម្រេចមើល ថាតើមានសេវាបន្ថែមផ្សេងៗបែបណាខ្លះទៀត អាចពង្រឹងសមត្ថភាពរបស់លោកអ្នក ដើម្បីអាចផ្តល់លំនៅដ្ឋានមួយមានសុវត្ថិភាពជូនកូនរបស់លោកអ្នក។

តុលាការប្រហែលជាអាចសម្រេចថា ឥឡូវនេះមានសុវត្ថិភាពល្មមសមរម្យ អាចអនុញ្ញាតឲ្យកូនរបស់លោកអ្នកវិលទៅរស់នៅឯផ្ទះរបស់លោកអ្នកបានវិញ ក្រោមការពិនិត្យឃ្លាំមើលពីសម្នាក់តុលាការ។

**12 ខែ**

### សវនាការរៀបចំផែនការជាអចិន្ត្រៃយ៍

តុលាការនឹងសម្រេចអំពីផែនការរស់នៅអចិន្ត្រៃយ៍របស់កូនលោកអ្នកគួរជាផែនបែបណា ហើយផែនរួមសព្វថ្ងៃជាផែនការបែបណា ប្រសិនបើលោកអ្នកមិនអាចផ្តល់ការចិញ្ចឹមបីបាច់ដោយសុវត្ថិភាពទេនោះ។

**18 ខែ**

### សវនាការពិនិត្យមើលករណីកូនក្រោមបន្ទុកឡើងវិញ
(ជាបន្តរៀងរាល់ 6 ខែម្តង)

តុលាការនឹងពិនិត្យមើលការចូលរួមរបស់លោកអ្នកឡើងវិញ ហើយបើលោកអ្នកពុំមានការរីកចម្រើនសមល្មមនៅពេលនេះទេ, នោះតុលាការតុលាការ (នៅក្នុងករណីខ្លះ) ដែលរដ្ឋបានដាក់បណ្តឹងលិខិតប្តឹង ដើម្បីដកសិទ្ធិចិញ្ចឹមបីបាច់កូនរបស់លោកអ្នក។

បើបណ្តឹងលិខិតដកសិទ្ធិរបស់លោកអ្នកត្រូវបានដាក់ប្តឹងទៅតុលាការ, នោះនឹងមានការជំនុំជម្រះក្តី ដែលមេធាវីរបស់លោកអ្នក និងមេធាវីរបស់រដ្ឋនឹងបង្ហាញត្រូវភស្តុតាងលើសំណុំរឿងរបស់លោកអ្នក។ ចៅក្រមនឹងវិនិច្ឆ័យមើល ថាតើត្រូវដកឬមិនត្រូវដកសិទ្ធិចិញ្ចឹមបីបាច់កូនរបស់លោកអ្នក។

## ការប្រជុំដើម្បីរៀបចំផែនការរួម

ការចូលរួមរបស់លោកអ្នកក្នុងគ្រប់អង្គប្រជុំរៀបចំផែនការរួមរបស់នាយកដ្ឋានគ្រប់គ្រងកុមារមានសារសំខាន់ណាស់។ លោកអ្នកនឹងជួយអភិវឌ្ឍន៍ផែនការសំណុំរឿងគ្រួសាររបស់អ្នក ដើម្បីលុបបំបាត់ការគំរាមកំហែងសុវត្ថិភាពរបស់ក្មេង ហើយបង្កើតគោលដៅអចិន្ត្រៃយ៍សម្រាប់កូនរបស់លោកអ្នក។

### ការធ្វើសេចក្តីសម្រេចរបស់ក្រុមការងារគ្រួសារ (FTDM)

ការប្រជុំ FTDM ត្រូវធ្វើឡើងរហូតមួយជីវិតនៃសំណុំរឿង។ ពួកគេប្រមូលសមាជិកគ្រួសារ ក្រុមទ្រទ្រង់ និងពួកអ្នកមានវិជ្ជាជីវៈមកចូលរួមប្រជុំជាមួយគ្នា ដើម្បីធ្វើសេចក្តីណែនាំអំពីការដាក់កូនរបស់លោកអ្នក ឲ្យគេជួយចិញ្ចឹមជាបណ្តោះអាសន្ន និងជាអចិន្ត្រៃយ៍។

### ក្រុមការពារកុមារ (CPT)

ក្រុមការពារកុមាររួមមានវេជ្ជបណ្ឌិត, បុគ្គលិកសាលារៀន, គិលានុបដ្ឋាកគាំពារសុខភាពផ្លូវសតិ, និងពួកអ្នកមានវិជ្ជាជីវៈសហគមន៍ដទៃៗទៀត។ បុគ្គលទាំងនេះចូលរួមគ្នាផ្តល់ការប្រឹក្សាយោបល់ និងអនុសាសន៍ជាសម្ងាត់ដល់នាយកដ្ឋានគ្រប់គ្រងស្តីពីសំណុំរឿងទាំងឡាយណា ដែលនាំឲ្យក្មេងអាយុពីប្រាំមួយឆ្នាំចុះ មានការប្រឈមនឹងគ្រោះ, ដែលនាំឲ្យមានជម្លោះណាមួយស្តីពីតម្រូវដាក់ក្មេងឲ្យគេជួយចិញ្ចឹមនៅក្រៅផ្ទះ។

### ការរៀបចំផែនការអចិន្ត្រៃយ៍ និងព្រមៗគ្នា

បន្ថែមលើការធ្វើការជាមួយលោកអ្នក ដើម្បីកាត់បន្ថយ ឬលុបបំបាត់នូវការគំរាមកំហែងសុវត្ថិភាពក្មេង, នោះបុគ្គលិកនាយកដ្ឋានគ្រប់គ្រងកុមារនឹងធ្វើការជាមួយលោកអ្នក ដើម្បីអភិវឌ្ឍន៍គោលដៅនៃផែនការសំណុំរឿសម្រាប់ការចិញ្ចឹមរយៈពេលខ្លី និងរយៈពេលវែង។ គោលដៅដំបូងរបស់យើងគឺគ្រល់កូនរបស់លោកអ្នក ជូនលោកអ្នកចិញ្ចឹម ប៉ុន្តែយើងក៏ត្រូវតែមានផែនការ(ព្រមៗគ្នា)ណាមួយផ្សេងទៀត ប្រសិនបើគោលដៅនៃផែនការសំណុំរឿងមិនទទួលបានជោគជ័យទេនោះ។

### ការប្រឹក្សាយោបល់ខាងផ្នែកសុខុមាពកុមារឥណ្ឌានក្នុងមូលដ្ឋាន (LICWAC)

បើលោកអ្នក ឬកូនរបស់លោកអ្នកត្រូវបានគេរកឃើញថាជាជនជាតិដើមអាមេរិកាំង ឬអាចជាជនជាតិដើមអាមេរិកាំង, នោះសំណុំរឿងលោកអ្នកអាចនឹងត្រូវកាន់កាប់ដោយគណៈកម្មការប្រឹក្សាយោបល់ខាងផ្នែកសុខុមាលភាពកុមារឥណ្ឌានក្នុងមូលដ្ឋាន (Local Indian Child Welfare Advisory Committee)។ LICWAC គឺជាក្រុមអ្នកស្ម័គ្រចិត្ត ដែលកាន់កាប់ និងផ្តល់ការប្រឹក្សាយោបល់លើសំណុំរឿង CA នៅពេលណាស្ថានភាពជនជាតិអាមេរិកាំងដើមរបស់លោកអ្នកមិនទាន់បានកំណត់នៅឡើយ ឬគេមិនស្គាល់ឈ្មោះកុលសម្ព័ន្ធក្មេង។